

unicef for every child

# ការធ្វើឱ្យកុមារមានសុវត្ថិភាពនៅលើប្រព័ន្ធអនឡាញ ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ១៩ និងការស្តារឡើងវិញ

## មគ្គុទ្ទេសក៍ណែនាំសម្រាប់ប្រតិបត្តិករទូរស័ព្ទចល័ត និង អ្នកផ្តល់សេវាមាតិកាអនឡាញ

© UNICEF/UN014971/Estey

ការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ កំពុងបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៅទូទាំងពិភពលោក។ វិធានការដែលត្រូវបានអនុវត្តដើម្បីទប់ស្កាត់ការរីករាលដាលនៃវីរុសកូវីដ១៩ មានសារៈសំខាន់ខ្លាំងណាស់ ចំពោះសុខភាពរបស់ប្រជាពលរដ្ឋនៅក្នុងពិភពលោក ប៉ុន្តែវិធានការមួយចំនួនក៏មានសក្តានុពលក្នុងការបង្កឱ្យមានហានិភ័យកាន់តែខ្ពស់ចំពោះកុមារផងដែរ។

ប្រជាជនចំនួនមួយភាគបីទូទាំងសកលលោក កំពុងស្ថិតក្រោមបំរាមគោចរដោយសារជំងឺកូវីដ១៩និង ការបិទសាលារៀនបានបង្កផលប៉ះពាល់ដល់កុមារជាង ១,៥ ពាន់លាននាក់។ ការរិតបន្តឹងទៅលើការបំលាស់ទី ការបាត់បង់ប្រាក់ចំណូល ការរក្សាគម្លាតសង្គម និងភាពកកកុញហួសប្រមាណ ដែលអាចរួមចំណែកធ្វើឱ្យមានបញ្ហាតានតឹង និងការថប់បារម្ភកាន់តែខ្លាំងឡើង ដែលកំពុងតែបង្កើនលទ្ធភាពដល់កុមារអាចទទួលបទពិសោធន៍ និងមើលឃើញការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទនៅឯផ្ទះ ជាពិសេសគឺកុមារដែលកំពុងរស់នៅក្នុងស្ថានភាពគ្រួសារពោរពេញដោយអំពើហិង្សា ឬគ្រួសារដែលបាត់បង់ប្រក្រតីភាព។ បើទោះបីជាសហគមន៍អនឡាញបានដើរតួនាទីសំខាន់ក្នុងការរក្សាការរៀនសូត្រ កិច្ចគាំទ្រ និងការលេងកំសាន្តរបស់កុមារក៏ដោយ ប៉ុន្តែវាក៏កំពុងធ្វើឱ្យកុមារកាន់តែប្រឈមទៅនឹងការរុកកួនផែផៅនៅតាមប្រព័ន្ធអនឡាញ អាកប្បកិរិយាដែលងាយរងគ្រោះ និងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញផងដែរ។[1]




នៅក្នុងប្រទេសកម្ពុជា អាស្រ័យដោយទាំងគ្រឹះស្ថានសិក្សារដ្ឋ និងឯកជនទាំងអស់បានផ្អាកដំណើរការចាប់តាំងពីខែមីនា និងដោយមានការកំណត់ឱ្យរក្សាគម្លាតសង្គម កុមារ និងក្មេងជំទង់ជាច្រើនកំពុងចំណាយពេលវេលារបស់ពួកគេភាគច្រើនឬទាំងអស់នៅឯផ្ទះ។ ពេលវេលាជាច្រើនរបស់ពួកគេអាចចំណាយនៅលើប្រព័ន្ធអនឡាញ និងជារឿយៗរមែងតែងមានរយៈពេលយូរជាងធម្មតា។ មុនពេលចាប់ផ្តើមមានវិបត្តិកូវីដនេះ ប្រទេសកម្ពុជាមានការប្រើប្រាស់អ៊ីនធឺណែតក្នុងកម្រិតខ្ពស់រួចទៅហើយ ពោលគឺជាអ្នកប្រើប្រាស់បណ្តាញសង្គមសកម្ម ដែលត្រូវបានគេប៉ាន់ប្រមាណថាមានចំនួន ៨,៤លាននាក់ ក្នុងចំណោមចំនួនប្រជាជនសរុប ១៦,៣៦លាននាក់ ខណៈពេលដែលចំនួនអ្នកប្រើប្រាស់អ៊ីនធឺណែត បានកើនឡើងចំនួន ៥៦% នៅចន្លោះខែមករាឆ្នាំ២០១៨ទៅខែមករាឆ្នាំ២០១៩ និងត្រូវបានប៉ាន់

[1] សេចក្តីថ្លែងការណ៍របស់មេដឹកនាំ៖ អំពើហិង្សាលើកុមារ៖ វិបត្តិលាក់កំបាំងនៃការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ ថ្ងៃទី៨ ខែមេសាឆ្នាំ២០២០

ប្រមាណថាមានចំនួន១២,៥លាននាក់។ នៅពេលដែលមានការប្រកាសអំពីការរិតបន្តឹង គេរំពឹងថាការប្រើប្រាស់អ៊ីនធឺណែតនឹងកើនឡើងគួរឱ្យកត់សម្គាល់។

ហ្វេសប៊ុក នៅតែបន្តជាជម្រើសសម្រាប់ពលរដ្ឋកម្ពុជា ដោយមានអ្នកប្រើប្រាស់ ហ្វេសប៊ុក ចំនួន ៧.៨១០.០០០នាក់ (គិតត្រឹមខែមេសាឆ្នាំ២០១៩) ដែលស្មើនឹង ៤៦,៥%នៃចំនួនប្រជាជនសរុបរបស់កម្ពុជា។ អ្នកប្រើប្រាស់ហ្វេសប៊ុកភាគច្រើននៅកម្ពុជាមានអាយុចន្លោះពី១៣ឆ្នាំទៅ៣៤ឆ្នាំ។ ប្រព័ន្ធទំនាក់ទំនងសង្គមដទៃទៀត ដែលមានឥទ្ធិពលតាមលំដាប់លំដោយរួមមាន៖ YouTube (អ្នកប្រើប្រាស់ចំនួន ១.៩០០ពាន់នាក់) Instagram (អ្នកប្រើប្រាស់ចំនួន ៧២០ពាន់នាក់) TikTok (អ្នកប្រើប្រាស់ចំនួន ៥០០ពាន់នាក់) Linkedin (អ្នកប្រើប្រាស់ចំនួន ៣៣០ពាន់នាក់) Twitter (អ្នកប្រើប្រាស់ចំនួន២០០ពាន់នាក់) និងTelegram ដែលគ្មានទិន្នន័យ ប៉ុន្តែវាគឺជាជម្រើស និងមធ្យោបាយសម្រាប់ផ្ញើសាររបស់មន្ត្រីរដ្ឋាភិបាលកម្ពុជា។ ការប្រើប្រាស់ Instagram និង TikTok កំពុងមានការកើនឡើងដោយមានការពេញនិយមក្នុងចំណោមអ្នកប្រើប្រាស់វ័យក្មេងខណៈពេលដែល Linkedin និង Twitter មានភាពទាក់ទាញសម្រាប់អ្នកវិជ្ជាជីវៈវ័យក្មេង និង វិស័យការងារអភិវឌ្ឍន៍។[2]




ការពិគ្រោះយោបល់ជាមួយយុវជន និងកុមារនាពេលថ្មីៗនេះដែលធ្វើឡើងដោយ Joining Forces និងអង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា ក៏បានលើកឡើងអំពីញ្ហាសុវត្ថិភាពកុមារនៅលើប្រព័ន្ធអនឡាញផងដែរ។ ទិន្នន័យដែលប្រមូលបានក្នុងពេលពិគ្រោះយោបល់នេះបានបង្ហាញឱ្យដឹងថា ដោយសារពួកគេមានពេលវេលាទំនេរច្រើនជាងមុន កុមារ និងក្មេងជំទង់ ៨៤%បានចំណាយពេលវេលានៅលើប្រព័ន្ធអនឡាញច្រើនជាងមុន។ ការចំណាយពេលលើប្រព័ន្ធអ៊ីនធឺណែតច្រើនជាងមុននោះ គឺគ្មានការត្រួតពិនិត្យទេ។ ទាំងនេះហើយដែលនាំមកនូវបញ្ហាប្រឈមធ្ងន់ធ្ងរចំពោះកិច្ចការពារកុមារ។ នៅក្នុងការពិគ្រោះយោបល់ដដែលនេះ ១៥%នៃកុមារទាំងអស់ដែលត្រូវបានសម្ភាសន៍បានរាយការណ៍ឱ្យដឹងថា ពួកគេធ្លាប់ត្រូវបានមនុស្សមិនធ្លាប់ស្គាល់ទាក់ទងមកកាន់ពួកគេនៅលើបណ្តាញសង្គម និង ២% បានរាយការណ៍ឱ្យដឹងថាធ្លាប់ត្រូវបានគេស្នើសុំឱ្យចែករំលែករូបភាពឬវីដេអូបែបស្និទ្ធស្នាលឬ ធ្វើសកម្មភាពមិនសមរម្យ នៅចំពោះមុខកាំម៉េរ៉ាដែលភ្ជាប់ទៅនឹងអ៊ីន

---

2 https://napoleoncat.com/stats/facebook-users-in-cambodia/2019/04;http://geeksincambodia.com/cambodias-2019-social-media-digital-statistics/

ជីណែត។ កុមារ និងក្មេងវ័យជំទង់ក្នុងចំនួនភាគរយស្រដៀងគ្នានេះ ក៏បានរាយការណ៍ឱ្យដឹងផងដែរថា ពួកគេធ្លាប់បានក្លាយខ្លួនជាជនរងគ្រោះឬបានឃើញការរុកគួនឆែឆៅនៅតាមអ៊ីនធឺណែត ចាប់ពីពេលសាលារៀនត្រូវបានផ្អាកដំណើរការក្នុងប្រទេសកម្ពុជា។[3]

ចំពោះកុមារ វាអាចជាការសិក្សារៀនសូត្រពីចម្ងាយ (ប្រសិនបើសាលារៀន ឬ គ្រូបង្រៀនរបស់ពួកគេផ្តល់ជូន) ប៉ុន្តែក៏អាចជាការដែលគ្រាន់តែជជែកគ្នាលេងជាមួយមិត្តភក្តិ ការលេងល្បែងកម្សាន្ត ការបង្ហោះនៅលើបណ្តាញសង្គម ការចូលមើលគេហទំព័រ និងការចូលមើលព័ត៌មាន និងស្វែងរកកិច្ចគាំទ្រ។ ការដែលអាចមានលទ្ធភាពភ្ជាប់ទំនាក់ទំនងតាមអនឡាញ/អ៊ីនធឺណែត ផ្តល់នូវឱកាសដ៏មានតម្លៃដើម្បីសិក្សារៀនសូត្រ លេង និងប្រាស្រ័យទាក់ទងក្នុងសង្គមជាមួយមិត្តភក្តិ ព្រមទាំងទទួលបានព័ត៌មាន និងកិច្ចគាំទ្រ ដូច្នេះវាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់កុមារ និងក្មេងជំទង់។

បើទោះជាដូច្នេះក្តី ពុំមែនតែឱកាសវិជ្ជមាន និងប្រកបដោយភាពស្ថាបនាប៉ុណ្ណោះទេដែលកើតមាន ប៉ុន្តែក៏មានការគំរាមកំហែង និងគ្រោះថ្នាក់នៅលើប្រព័ន្ធអនឡាញ/អ៊ីនធឺណែតផងដែរ។ ខាងក្រោមនេះគឺជាហានិភ័យមួយចំនួនចំពោះកុមារនៅលើប្រព័ន្ធអនឡាញ/អ៊ីនធឺណែត ដែលមន្ត្រីអនុវត្តច្បាប់ និងអ្នកអនុវត្តការងារកិច្ចការពារកុមារ រំពឹងថាអាចនឹងកើនឡើង ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ១៩៖

- **ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ៖** ការចំណាយពេលច្រើនលើប្រព័ន្ធអនឡាញ/អ៊ីនធឺណែតអាចបង្កើនហានិភ័យនៃការប្រាស្រ័យទាក់ទងជាមួយមនុស្សពេញវ័យ ឬ កុមារដទៃទៀត ដែលមានវ័យច្រើនជាងដែលមានចំណាប់អារម្មណ៍ផ្លូវភេទជាមួយកុមារ។ កុមារអាចទំនងនឹងជជែកលេងជាមួយមនុស្សដែលជាធម្មតាពួកគេមិនធ្លាប់ជជែកជាមួយ ដោយសារតែពួកគេចំណាយពេលលើប្រព័ន្ធអនឡាញ/អ៊ីនធឺណែត ច្រើនជាងមុន និងដោយសារមានការព្រួយបារម្ភ ឬ មានក្តីកង្វល់អំពីអ្វីដែលកំពុងកើតឡើងជុំវិញខ្លួនពួកគេ។ សម្ពាធផ្នែកសង្គមសេដ្ឋកិច្ច ក៏អាចនាំឱ្យកុមាររងសម្ពាធដើម្បីស្វែងរកវិធីរកប្រាក់បន្ថែមសម្រាប់ខ្លួនឯង ឬ គ្រួសាររបស់ពួកគេផងដែរ។ កុមារអាចត្រូវបានទាក់ទងដោយជនដែលពួកគេមិនដែលស្គាល់ ឬ ជនស្គាល់គ្នាដែលអាចមានចំណាប់អារម្មណ៍ផ្លូវភេទលើកុមារ។

  ពួកគេអាចត្រូវបានគេបញ្ជូនមាតិកាពាក់ព័ន្ធទៅនឹងបញ្ហាផ្លូវភេទ ឬ ត្រូវបានស្នើសុំឱ្យចែករំលែករូបភាព និងវីដេអូរបស់ពួកគេដែលមានមាតិកាពាក់ព័ន្ធនឹងផ្លូវភេទរបស់កុមារ។ មនុស្សពេញវ័យអាចកសាងទំនាក់ទំនងជាមួយកុមារក្នុងគោលបំណងរំលោភបំពានផ្លូវភេទទៅលើពួកគេ (ដែលគេហៅថា"ល្បួង")។ ប្រព័ន្ធជជែកកម្សាន្ត រួមទាំងប្រព័ន្ធដែលត្រូវបានកំណត់គោលដៅទីផ្សារសម្រាប់កុមារអាចបង្កហានិភ័យជាក់លាក់ចំពោះកុមារ ដោយសារប្រព័ន្ធទាំងនេះជាច្រើនពុំមានលិខិតបទដ្ឋានគតិយុត្តិគ្រប់គ្រងឱ្យបានល្អប្រសើរនៅឡើយ។ ការរាយការណ៍ពីមជ្ឈមណ្ឌលជាតិការពារកុមារដែលបានបាត់ខ្លួន និងរងគ្រោះដោយការកេងប្រវ័ញ្ច (NCMEC) ទៅការិយាល័យស៊ើបអង្កេតសហព័ន្ធ និងក្រសួងសន្តិសុខមាតុភូមិនៃសហរដ្ឋអាមេរិក (HSI) ប្រចាំរាជធានីភ្នំពេញចាប់ពីខែមករា រហូតដល់ ខែវិច្ឆិកាឆ្នាំ២០១៨ បង្ហាញឱ្យឃើញអំពីការកើនឡើងចំនួន៤៩០% នៃសេចក្តីរាយការណ៍អំពីសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ (ពីចំនួន២៥.៣៣២ក្នុងឆ្នាំ២០១៧រហូតដល់ចំនួន ១២៣.៨៩៦ក្នុងរយៈពេល១១ខែដំបូង នៃឆ្នាំ២០១៨)។[4]

---

[3] អង្គការឆាលហ្វាន់ អង្គការផ្លែនអន្តរជាតិ អង្គការសង្គ្រោះកុមារអន្តរជាតិ អេស អូ អេស ភូមិកុមារកម្ពុជា Terre des Hommes Netherlands និងអង្គការទស្សនៈពិភពលោកអន្តរជាតិ "សេចក្តីថ្លែងការណ៍រួមសាធារណៈ" ៖ ម្ចាស់ជំនួយ និង រដ្ឋាភិបាលត្រូវបញ្ចូលបញ្ហាសិទ្ធិកុមារជាធាតុស្នូលនៃការឆ្លើយតបចំពោះជំងឺកូវីដ១៩" កម្ពុជា ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០។

[4] ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ "ការវិភាគស្ថានភាពបឋមអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមអនឡាញ (OCSE) នៅកម្ពុជា" កម្ពុជា ២០១៩។

- **ការរុកគួនឆាផៅនៅតាមប្រព័ន្ធអនឡាញ៖** កុមារអាចទទួលបាន ឬ ក្លាយជាកម្មវត្ថុនៃការលើកឡើងនូវយោបល់សារ និងការបង្ហោះព័ត៌មានអាក្រក់ៗ។ ពួកគេអាចត្រូវបានទុកចោលក្នុងក្រុមអនឡាញ។ ការធ្វើបែបនេះអាចនាំឱ្យវិបត្តិតានតឹង និងការមានអារម្មណ៍ឯកោកើនឡើង។ ពួកគេក៏អាចចូលរួមនៅក្នុងការសម្លុត ការរុកគួនឆាផៅនៅតាមប្រព័ន្ធអនឡាញដោយខ្លួនឯងផងដែរ។

- **អាកប្បកិរិយាប្រថុយប្រថានលើប្រព័ន្ធអនឡាញ៖** ការរក្សាគម្លាតសង្គម និងកង្វះការប្រាស្រ័យទាក់ទងផ្ទាល់ជាមួយមិត្តភក្តិ និងការថយចុះនូវការយល់ចិត្តពីអ្នកពាក់ព័ន្ធ អាចនាំឱ្យកុមារហ៊ានប្រថុយប្រថាន ឬ ធ្វើអ្វីដែលពួកគេទំនងមិនធ្វើនៅលើប្រព័ន្ធអនឡាញ ឧទាហរណ៍ដូចជា តាមរយៈការផ្ញើសារដែលមានអត្ថន័យផ្លូវភេទ និងការចែករំលែករូបថត និងវីដេអូអាក្រាត និងពាក់ព័ន្ធផ្លូវភេទ។ ក្រោយមករូបភាពរបស់ពួកគេ អាចត្រូវបានអ្នកដទៃយកទៅធ្វើការចែករំលែកដោយគ្មានការយល់ព្រមពីពួកគេ។ ហើយពួកគេអាចប្រឈម ទៅនឹងការជំរិត ការបង្ហោះរូបភាព ឬវីដេអូអាក្រាតដោយអតីតដៃគូ ការបៀតបៀន និងការបង្កភាពអាម៉ាស់។ ការផ្ញើ និងការទទួលមាតិកាអាសអាភាសក៏អាចប្រឈមទៅនឹងផលវិបាកផ្នែកព្រហ្មទណ្ឌផងដែរ។ កង្វះការយល់ដឹងជាទូទៅអំពីដែនកំណត់ដើម្បីរក្សាភាពឯកជន និងវិធានសុវត្ថិភាពព្រមទាំងការដែលកុមារមានអារម្មណ៍អាម៉ាស់នៅពេលទទួលបានសម្ភារៈអាសអាសភាសដែលពួកគេមិនបានស្នើសុំ ការទទួលវីដេអូខលដែលមិនសមស្រប ឬ ការដែលត្រូវបានស្នើសុំឱ្យចែករំលែករូបភាព ទំនងនឹងបង្កហានិភ័យខ្ពស់សម្រាប់ពួកគេផងដែរ។

- **មាតិកាដែលជាសក្តានុពលក្នុងការបង្កគ្រោះថ្នាក់៖** ចំណុចនេះរាប់បញ្ចូលការចូលមើល ការដែលត្រូវបានគេផ្ញើ និងការចែករំលែកមាតិកាប្រកបដោយគ្រោះថ្នាក់ ដូចជា៖ ការញុះញង់ឱ្យធ្វើអត្តឃាត និងបង្កគ្រោះថ្នាក់ចំពោះខ្លួនឯង មាតិកាហិង្សា ឬមាតិការើសអើងជាតិសាសន៍ និងការធ្វើទីផ្សារដែលមិនសមស្របសម្រាប់កុមារ។ កុមារក៏អាចប្រឈមទៅនឹងការផ្តល់ព័ត៌មានមិនត្រឹមត្រូវអំពីជំងឺកូវីដ១៩ដែលធ្វើឱ្យពួកគេកាន់តែភ័យខ្លាចអន្ទះសារ និងភាន់ច្រឡំអំពីពិភពរបស់ពួកគេផងដែរ។

- **ភាពឯកជនរបស់កុមារក៏អាចមានហានិភ័យខ្ពស់ជាងមុនផងដែរ៖** បើទោះបីជាការរៀនសូត្រតាមប្រព័ន្ធ អេឡិកត្រូនិក និងការបង្រៀនពីចម្ងាយតាមរយៈកម្មវិធីមួយចំនួនដូចជា Zoom ឬ Google ផ្តល់នូវឱកាសដ៏អស្ចារ្យដើម្បីឱ្យកុមាររក្សាបាននូវការរៀនសូត្រ និងការបញ្ចប់កម្មវិធីសិក្សាជាផ្លូវការក៏ដោយ ប៉ុន្តែកម្មវិធីជាច្រើនដែលត្រូវបានប្រើប្រាស់សម្រាប់ការរៀនសូត្រ ក៏បង្កនូវហានិភ័យទៅលើភាពឯកជនចំពោះអ្នកប្រើប្រាស់ព្រមទាំងអាចនាំឱ្យប៉ះពាល់ដល់ទិន្នន័យរបស់ពួកគេ ឬ ព័ត៌មានលម្អិតផ្ទាល់ខ្លួន និងព័ត៌មានដែលជាធម្មតាមិនចែករំលែកនៅលើប្រព័ន្ធអនឡាញ ក្លាយទៅជាព័ត៌មានដែលគេអាចចូលមើល និងកេងប្រវ័ញ្ចបានយ៉ាងងាយ។ កម្មវិធីវីដេអូនាំឱ្យគេអាចមើលឃើញបរិយាកាសនៅក្នុងផ្ទះ (មិនចំពោះថាជាបន្ទប់គេង បន្ទប់ទទួលភ្ញៀវ ឬ កន្លែងដទៃទៀតនៅក្នុងផ្ទះ តាមរយៈវគ្គសិក្សាដែលបានធ្វើឡើង) ដែលរូបភាពទាំងនេះ មិនត្រឹមតែបើកចំហរឱ្យអ្នកដទៃនៅក្នុងថ្នាក់ ឬ មនុស្សពេញវ័យដែលអាចមានតួនាទីនៅក្នុងវគ្គសិក្សាបានឃើញឡើយ។ តំណភ្ជាប់ដែលគ្មានសុវត្ថិភាព និងតំណភ្ជាប់ដោយបំភាន់ ក៏អាចអនុញ្ញាតឱ្យអ្នកប្រើប្រាស់ដទៃទៀតអាចប្រមូលព័ត៌មានរបស់អ្នកប្រើប្រាស់ រួមទាំងអាស័យដ្ឋាន IP របស់កុំព្យូទ័រផងដែរ។

ហានិភ័យទាំងនេះ មិនមែនបង្កឡើងដោយជនដែលមិនធ្លាប់ស្គាល់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏បង្កឡើងដោយជនដែលកុមារធ្លាប់ស្គាល់រួចមកហើយនៅក្នុងនិងក្រៅប្រព័ន្ធអនឡាញ។

អាស្រ័យដោយហានិភ័យនៃគ្រោះថ្នាក់នៅលើប្រព័ន្ធអនឡាញមានកម្រិតខ្ពស់ ដូច្នេះប្រតិបត្តិករទូរស័ព្ទចល័តអាចដើរតួនាទីមួយដ៏សំខាន់ក្នុងការបង្ការ ការត្រួតពិនិត្យ និងការឆ្លើយតបចំពោះកិច្ចការពារកុមារនៅលើប្រព័ន្ធអនឡាញ ហើយពួកគេគប្បីធ្វើអ្វីគ្រប់យ៉ាងដែលអាចធ្វើទៅបានដើម្បីរក្សាសុវត្ថិភាពរបស់កុមារនៅលើប្រព័ន្ធអនឡាញ។ បណ្តាក្រុមហ៊ុននានាគប្បីរៀបចំឱ្យមានវិធានការដើម្បីស្វែងរកឱ្យឃើញ និងបញ្ឈប់សកម្មភាពបង្កគ្រោះថ្នាក់ចំពោះកុមារនៅលើប្រព័ន្ធអនឡាញ រាប់បញ្ចូលទាំងសកម្មភាពល្បួងកុមារ និងការបង្កើត និងចែកចាយរូបភាព និងវីដេអូរំលោភបំពានផ្លូវភេទលើកុមារ។

១. **ការអប់រំកុមារ ឪពុកម្តាយ និងគ្រូបង្រៀនអំពីសុវត្ថិភាពកុមារ និងការទទួលខុសត្រូវរបស់ពួកគេក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា៖** បង្កើន និងសម្របសម្រួលលទ្ធភាពទទួលបានប្រព័ន្ធរៀនសូត្រអំពីសុវត្ថិភាពកុមារ និងកិច្ចការពារនៅលើប្រព័ន្ធអនឡាញ រាប់បញ្ចូលតាមរយៈការផ្សព្វផ្សាយ និងការចែករំលែកសារអំពីសុវត្ថិភាពកុមារនៅលើប្រព័ន្ធអនឡាញ និងព័ត៌មានជាក់ស្តែងអំពីបណ្តាញរាយការណ៍ សម្រាប់ពេលដែលកុមារត្រូវការជំនួយ។ បណ្តាញទូរស័ព្ទផ្តល់ជំនួយ និងបណ្តាញទូរស័ព្ទទាន់ហេតុការណ៍សំខាន់ៗមួយចំនួន រួមមាន៖

- ✓ **១២៨៨៖** លេខទូរស័ព្ទទាន់ហេតុការណ៍សម្រាប់នគរបាលប្រឆាំងការជួញដូរមនុស្ស (២៤/៧)
- ✓ **១២៨០៖** បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា (CHC)។ បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជាធ្វើប្រតិបត្តិការសេវាបណ្តាញទូរស័ព្ទផ្តល់ជំនួយដោយឥតគិតថ្លៃ (២៤/៧) តាមរយៈការផ្តល់ប្រឹក្សាយោបល់តាមទូរស័ព្ទប្រកបដោយវិជ្ជាជីវៈ និង សេវាព័ត៌មានអប់រំ ព្រមទាំងភ្ជាប់ទំនាក់ទំនងកុមារ និងក្មេងជំទង់ទៅនឹងសេវាចាំបាច់នានា ដោយផ្អែកទៅតាមសេចក្តីត្រូវការ និង ការសម្រេចចិត្តរបស់ពួកគេ។
- ✓ **០១៧ ២២២ ៣៧២ / ០៨៩ ៦៦៦ ៣២៥ / ០៩៧ ៩១១១ ៩១៨ ឬ** www.facebook.com/tpocambodia **៖** បណ្តាញទូរស័ព្ទទាន់ហេតុការណ៍របស់អង្គការ TPO សម្រាប់កិច្ចគាំទ្រសុខភាពផ្លូវចិត្ត និងចិត្តសង្គម សម្រាប់កុមារ ឪពុកម្តាយ និងអ្នកថែទាំ។
- ✓ **០៩២ ៣១១ ៥១១ ឬ** https://aplecambodia.org/reportabuse/:
  បណ្តាញទូរស័ព្ទទាន់ហេតុការណ៍របស់អង្គការ APLE សម្រាប់រាយការណ៍អំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងសម្ភារពាក់ព័ន្ធការរំលោភបំពានផ្លូវភេទលើកុមារនៅលើប្រព័ន្ធអនឡាញ។
  អ្នកអាចរាយការណ៍ដោយអនាមិក (២៤/៧)។

២. **ការបង្កើតឱ្យមានបរិយាកាសអនឡាញមួយដែលមានសុវត្ថិភាព និងសមស្របទៅតាមអាយុ៖** ការលើកកម្ពស់ឱ្យមានការបើកចំហប្រកបដោយសុវត្ថិភាព និងភាពច្នៃប្រឌិតសម្រាប់កុមារនៅលើប្រព័ន្ធអនឡាញ រួមទាំងការសម្របសម្រួល និងកិច្ចគាំទ្រដល់បណ្តាញទូរស័ព្ទទាន់ហេតុការណ៍ខាងលើ និងការរាយការណ៍នៅលើប្រព័ន្ធអនឡាញអំពីបញ្ហានានា។ សកម្មភាពនេះរាប់បញ្ចូលការផ្តល់លទ្ធភាពទទួលបានបណ្តាញទូរស័ព្ទផ្តល់ជំនួយដោយឥតគិតថ្លៃ សេវាដែលមានភាពសមស្របទៅតាមអាយុ និងប្រព័ន្ធអប់រំតាមប្រព័ន្ធអេឡិកត្រូនិកប្រកបដោយសុវត្ថិភាព ព្រមទាំងការប្រើប្រាស់ប្រព័ន្ធរបស់ពួកគេដើម្បីផ្តល់ដំបូន្មានអំពីសុវត្ថិភាពរបស់កុមារនៅលើប្រព័ន្ធអនឡាញ និងការឃ្លាំមើលរបស់ឪពុកម្តាយទៅលើសកម្មភាពអនឡាញរបស់កូន។

៣. **ការអភិវឌ្ឍបទដ្ឋានដើម្បីដោះស្រាយបញ្ហាសម្ភារពាក់ព័ន្ធការរំលោភបំពានលើកុមារ៖** កិច្ចសហការដ៏រឹងមាំរវាងវិស័យឯកជននិងមន្ត្រីអនុវត្តច្បាប់ គឺជាគន្លឹះមួយដើម្បីធានាឱ្យបាននូវការរកឃើញដំបូងឱ្យបានឆាប់រហ័សនូវករណីបទល្មើសបច្ចេកវិទ្យាព្រមទាំងការបិទ និងការដកចេញប្រកបដោយប្រសិទ្ធភាពនូវសម្ភារៈកេងប្រវ័ញ្ចផ្លូវភេទកុមារនៅលើប្រព័ន្ធអនឡាញ។ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា និង នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃ គឺជាទីភ្នាក់ងារអនុវត្តច្បាប់ ដែលមានអាណត្តិការងារការពារកុមារពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទនៅលើប្រព័ន្ធអនឡាញ ដោយមានកិច្ចសហប្រតិបត្តិការជាមួយអង្គភាពថ្នាក់តំបន់ និងអន្តរជាតិ ដូចជាអង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិ (INTERPOL) និងការិយាល័យស៊ើបអង្កេតសហព័ន្ធ (FBI)។ ពិធីសារ និងដំណើរការច្បាស់លាស់ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ នឹងជួយលើកកម្ពស់សមត្ថភាពដល់ទីភ្នាក់ងារអនុវត្តច្បាប់ក្នុងការស៊ើបអង្កេត និងបង្ក្រាបអំពើរំលោភបំពាន និងអំពើកេងប្រវ័ញ្ចផ្លូវភេទកុមារនៅលើប្រព័ន្ធអនឡាញ/អ៊ីនធឺណែត។

៤. **ការបញ្ចូលការពិចារណាអំពីបញ្ហាសិទ្ធិកុមារទៅក្នុងរាល់គោលនយោបាយ និងដំណើរការគ្រប់គ្រងសារជីវកម្មសមស្រប៖** ការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយស្តីពីកិច្ចការពារកុមារនៅលើប្រព័ន្ធអនឡាញ/អ៊ីនធឺណែតនៅក្នុងស្ថាប័ន។ ព័ត៌មានបន្ថែមអំពីរបៀបអភិវឌ្ឍគោលនយោបាយ និងដំណើរការទាំងនេះ អាចរកមើលបាននៅលើគេហទំព័រស្តីពីសិទ្ធិកុមារ និងធុរកិច្ច៖ https://www.unicef.org/csr/ict.html ។

៥. **ការលើកកម្ពស់បច្ចេកវិទ្យាឌីជីថលក្នុងលក្ខណៈជាមធ្យោបាយសម្រាប់បង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ៖** ក្រុមហ៊ុននានាអាចគាំទ្រដល់ការចូលរួមរបស់កុមារ និងយុវជនតាមរយៈការចូលរួមប្រកបដោយភាពច្នៃប្រឌិត និងភាពវិជ្ជមានអំពីប្រធានបទសំខាន់ៗស្តីពីកិច្ចការពារកុមារដោយរាប់បញ្ចូលការលើកកម្ពស់អក្ខរភាពឌីជីថលសម្រាប់កុមារ និងឪពុកម្តាយរបស់ពួកគេ។ ក្រុមហ៊ុនក៏អាចជួយលើកកម្ពស់ការចែករំលែកគំនិតយោបល់ និងទេពកោសល្យរបស់កុមារ អំពីរបៀបការគ្រប់គ្រងពេលវេលារបស់ពួកគេ ក្នុងអំឡុងពេលនៃការរក្សា គម្លាតសង្គម វិធីដោះស្រាយវិបត្តិតានតឹងអារម្មណ៍ វិធីកសាងទំនាក់ទំនងឱ្យកាន់តែប្រសើរនៅក្នុងគ្រួសារ និងរបៀបដែលកុមារអាចចាត់វិធានការដើម្បីគាំទ្រដល់សង្គម ក្នុងអំឡុងពេលនៃការផ្ទុះរាលដាលនៃជំងឺកូវីដ១៩ រាប់បញ្ចូលទាំងតាមរយៈការចែករំលែកព័ត៌មានដើម្បីជួយដល់ខ្លួនឯង និងកុមារដទៃដើម្បីដោះស្រាយបញ្ហាការគំរាមកំហែងនៅលើប្រព័ន្ធអនឡាញដែលពួកគេអាចជួបប្រទះ ឬ អ្វីដែលត្រូវធ្វើប្រសិនបើពួកគេដឹងអំពី អំពើរំលោភបំពានទម្រង់ណាមួយរបស់មិត្តភក្តិ និងសមាជិកគ្រួសារពួកគេ។ មានប្រព័ន្ធ និងការផ្តួចផ្តើមមួយចំនួនដែលលើកកម្ពស់ការចូលរួមរបស់ក្មេងជំទង់ និងយុវជនក្នុងប្រទេសកម្ពុជាដូចជា កម្មវិធីសម្លេងយុវជន (https://voicesofyouthcambodia.com/) អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា (https://crc-cambodia.org/) និង បណ្តាញកុមារអ្នកតស៊ូមតិ (https://www.facebook.com/childadvocatenetwork/)។

## ធនធានឯកសារមួយចំនួនដែលមានសារៈប្រយោជន៍៖

*COVID-19 and its implications for protecting children online, April 2020:*
*https://www.unicef.org/documents/covid-19-and-implications-protecting-children-online*

*Guideline for Mobile Industry on child online protection (2015 edition):*
*https://www.unicef.org/csr/css/Mobile_Operators_COP_Guidelines_English1.pdf*

*TipsforParentsandCaregivers–KeepingChildrenSafeOnlineDuringtheCOVID-19 Pandemic*

*TipsforYoungPeople–StayingSafeOnlineDuringtheCOVID-19Pandemic*

*ECPAT Resources on Sexual Exploitation of Children for COVID-19 Situation:*
*https://ecpat.exposure.co/covid19?utm_source=Website&utm_campaign=Hero*

*NGO APLE's online resource center: https://www.internethotlinecambodia.org/*

unicef
for every child


ការិយាល័យអង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា
ជាន់ទី៥ អគារ Exchange Square បន្ទប់លេខ ១៩&២០ ផ្លូវលេខ១០៦
សង្កាត់វត្តភ្នំ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា